# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១៣១ អនក្រ.បក

ថ្ងៃទី 04 ខែ សីហា ឆ្នាំ 2025
ម៉ោង........នាទី ចុះលេខ 3885

## អនុក្រឹត្យ

## ស្តីពី

## ការរៀបចំអង្គភាពសវនកម្មផ្ទៃក្នុងក្រសួង ស្ថាប័ន ចំណុះអង្គភាពនីតិប្រតិបត្តិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦.នស.៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣០០/១០ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រងនិងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ១៦៨ អនក្រ.បក ចុះថ្ងៃទី៨ ខែតុលា ឆ្នាំ២០២០ ស្តីពីក្របខ័ណ្ឌមុខងារភារកិច្ចរបស់សវនកម្មផ្ទៃក្នុងនិងអធិការកិច្ច
- បានឃើញអនុក្រឹត្យលេខ២៦៥ អនក្រ.បក ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអង្គភាពសវនកម្មផ្ទៃក្នុង



តេឡេក្រាម ឯកសារមន្ត្រីសាធារណៈ

- បានឃើញអនុក្រឹត្យលេខ២៨៩ អនក្រ.បក ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៣ ស្ដីពីការគ្រប់គ្រងថវិកា និងគណនេយ្យសាធារណៈ
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

**សម្រេច**

**ជំពូកទី១**

**បទប្បញ្ញត្តិទូទៅ**

**មាត្រា១ .-**

អនុក្រឹត្យនេះ កំណត់អំពីការរៀបចំអង្គភាពសវនកម្មផ្ទៃក្នុងក្រសួង ស្ថាប័ន ចំណុះអង្គការនីតិប្រតិបត្តិ។

**មាត្រា២ .-**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះអង្គភាពសវនកម្មផ្ទៃក្នុងក្រសួង ស្ថាប័ន ចំណុះអង្គការនីតិប្រតិបត្តិ លើកលែងក្រសួងការពារជាតិ។

**ជំពូកទី២**

**តួនាទីនិងភារកិច្ច**

**មាត្រា៣ .-**

ក្រសួង ស្ថាប័ន មានអង្គភាពសវនកម្មផ្ទៃក្នុង ដើម្បីអនុវត្តតួនាទីនិងភារកិច្ចដែលបានកំណត់ក្នុងអនុក្រឹត្យលេខ២៦៥ អនក្រ.បក ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអង្គភាពសវនកម្មផ្ទៃក្នុង និងអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

អង្គភាពសវនកម្មផ្ទៃក្នុងក្រសួង ស្ថាប័ន មានតួនាទីនិងភារកិច្ចធ្វើសវនកម្មលើគ្រប់អង្គភាពក្រោមឱវាទក្រសួង ស្ថាប័ន លើកលែងតែមានការរៀបចំអង្គភាពសវនកម្មផ្ទៃក្នុងដោយឡែកនៅតាមអង្គភាពទាំងនោះ បន្ទាប់ពីមានការឯកភាពពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងមុខងារសាធារណៈ។

អង្គភាពសវនកម្មផ្ទៃក្នុងដែលមានស្រាប់នៅតាមសហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងអង្គភាពប្រហាក់ប្រហែល ត្រូវបន្តអនុវត្តតួនាទីនិងភារកិច្ចដដែលរហូតដល់មានការសម្រេចជាថ្មីពីរាជរដ្ឋាភិបាល។

**មាត្រា៤ .-**

ក្រសួង ស្ថាប័ន ត្រូវពិនិត្យនិងកែសម្រួលតួនាទីនិងភារកិច្ចរបស់អង្គភាពផ្សេងទៀតរបស់ក្រសួង ស្ថាប័ន ដែលត្រួតជាមួយអង្គភាពសវនកម្មផ្ទៃក្នុង ដោយផ្ទេរតួនាទីនិងភារកិច្ចនោះឱ្យទៅអង្គភាពសវនកម្មផ្ទៃក្នុង។

**ជំពូកទី៣**

**រចនាសម្ព័ន្ធ**

**មាត្រា៥ .-**

ក្រសួង ស្ថាប័ន ត្រូវរៀបចំរចនាសម្ព័ន្ធនៃអង្គភាពសវនកម្មផ្ទៃក្នុង ដូចមានចែងក្នុងមាត្រា៦ នៃអនុក្រឹត្យនេះ ដើម្បីអនុវត្តតួនាទីនិងភារកិច្ចដែលមានកំណត់នៅក្នុងអនុក្រឹត្យលេខ២៦៥ អនក្រ.បក ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអង្គភាពសវនកម្មផ្ទៃក្នុង។



តេឡេក្រាម ឯកសារមន្ត្រីសាធារណៈ

9

**មាត្រា៦ .-**

ក្រសួង ស្ថាប័ន ដែលមានអង្គភាពសវនកម្មផ្ទៃក្នុង និងអគ្គាធិការដ្ឋានឬអធិការដ្ឋាន ដែលបាននិងកំពុងអនុវត្តតួនាទីនិងភារកិច្ចត្រួតគ្នាដូចមានកំណត់នៅក្នុងអនុក្រឹត្យលេខ២៦៥ អនក្រ.បក ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអង្គភាពសវនកម្មផ្ទៃក្នុង ត្រូវធ្វើសមាហរណកម្មតួនាទីនិងភារកិច្ចអគ្គាធិការដ្ឋានឬអធិការដ្ឋានបញ្ចូលគ្នាជាមួយអង្គភាពសវនកម្មផ្ទៃក្នុងក្រសួង ស្ថាប័ន និងត្រូវរៀបចំរចនាសម្ព័ន្ធ ដូចខាងក្រោម៖

១- ក្រសួង ស្ថាប័ន ដែលមាននាយកដ្ឋានសវនកម្មផ្ទៃក្នុង និងមានអគ្គាធិការដ្ឋាន ដែលមាននាយកដ្ឋានចំណុះ ត្រូវរៀបចំកែសម្រួលដោយបញ្ចូលគ្នាទៅជាអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង ដែលមាននាយកដ្ឋានចំណុះយ៉ាងច្រើនត្រឹមចំនួនដែលមានស្រាប់។

២- ក្រសួង ស្ថាប័ន ដែលមាននាយកដ្ឋានសវនកម្មផ្ទៃក្នុង និងមានអគ្គាធិការដ្ឋាន ដែលមានផ្នែកឬការិយាល័យចំណុះ ឬមិនមានផ្នែកឬការិយាល័យចំណុះ ត្រូវរៀបចំកែសម្រួលដោយបញ្ចូលគ្នាទៅជាអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង ឬនាយកដ្ឋានសវនកម្មផ្ទៃក្នុង ដែលមានការិយាល័យចំណុះយ៉ាងច្រើនត្រឹមចំនួនដែលមានស្រាប់ផ្អែកលើទំហំការងាររបស់ក្រសួង ស្ថាប័នសាមី។

៣- ក្រសួង ស្ថាប័ន ដែលមាននាយកដ្ឋានសវនកម្មផ្ទៃក្នុង និងអធិការដ្ឋាន ត្រូវរៀបចំកែសម្រួលដោយបញ្ចូលគ្នា ទៅជានាយកដ្ឋានសវនកម្មផ្ទៃក្នុង ដែលមានការិយាល័យចំណុះយ៉ាងច្រើនត្រឹមចំនួនដែលមានស្រាប់។

**មាត្រា៧ .-**

ក្រសួង ស្ថាប័ន ដែលត្រូវរៀបចំអង្គភាពសវនកម្មផ្ទៃក្នុងតាមបទប្បញ្ញត្តិនៃមាត្រា៦ ចំណុចទី១ នៃអនុក្រឹត្យនេះ រួមមាន៖

- ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ក្រសួង ស្ថាប័ន ដែលត្រូវរៀបចំអង្គភាពសវនកម្មផ្ទៃក្នុងតាមបទប្បញ្ញត្តិនៃមាត្រា៦ ចំណុចទី២ នៃអនុក្រឹត្យនេះ កម្រិតអគ្គនាយកដ្ឋាន រួមមាន៖

- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងអភិវឌ្ឍន៍ជនបទ
- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- ក្រសួងរ៉ែនិងថាមពល
- ក្រសួងផែនការ
- ក្រសួងបរិស្ថាន
- ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

ក្រសួង ស្ថាប័ន ដែលត្រូវរៀបចំអង្គភាពសវនកម្មផ្ទៃក្នុងតាមបទប្បញ្ញត្តិនៃមាត្រា៦ ចំណុចទី២ នៃអនុក្រឹត្យនេះ កម្រិតនាយកដ្ឋាន រួមមាន៖ ក្រសួងកិច្ចការនារី។



តេឡេក្រាម ឯកសារមន្ត្រីសាធារណៈ

**មាត្រា៨ ..**

ក្រសួង ស្ថាប័ន ដែលមានអង្គភាពអនុវត្តតួនាទីនិងភារកិច្ចដាច់ដោយឡែកពីគ្នារវាងសវនកម្មផ្ទៃក្នុង និងអធិការកិច្ច ត្រូវបន្តអនុវត្តតួនាទីនិងភារកិច្ចដោយអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន រួមមាន៖

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងអប់រំ យុវជន និងកីឡា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងធនធានទឹកនិងឧតុនិយម
- ក្រសួងព័ត៌មាន
- ក្រសួងយុត្តិធម៌
- ក្រសួងអធិការកិច្ច
- ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- ក្រសួងសុខាភិបាល
- ក្រសួងសាធារណការនិងដឹកជញ្ជូន
- ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
- ក្រសួងទេសចរណ៍
- ក្រសួងធម្មការនិងសាសនា
- ក្រសួងមុខងារសាធារណៈ
- រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល
- រដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន។

ក្នុងករណីអង្គភាពរបស់ក្រសួង ស្ថាប័នខាងលើមានតួនាទីនិងភារកិច្ចណាមួយត្រួតគ្នាជាមួយអង្គភាពសវនកម្មផ្ទៃក្នុង ត្រូវអនុវត្តតាមបទប្បញ្ញត្តិនៃមាត្រា៤ នៃអនុក្រឹត្យនេះ។

**មាត្រា៩ ..**

ការរៀបចំនិងការប្រព្រឹត្តទៅនៃនាយកដ្ឋានឬអង្គភាពប្រហាក់ប្រហែលចំណុះអង្គភាពសវនកម្មផ្ទៃក្នុងក្រសួង ស្ថាប័ន ត្រូវកំណត់ដោយអនុក្រឹត្យតាមការស្នើរបស់ក្រសួង ស្ថាប័នសាមី បន្ទាប់ពីទទួលបានការឯកភាពជាមុនពីក្រសួងមុខងារសាធារណៈ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ការរៀបចំនិងការប្រព្រឹត្តទៅនៃការិយាល័យចំណុះអង្គភាពសវនកម្មផ្ទៃក្នុងក្រសួង ស្ថាប័ន ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួង ស្ថាប័នសាមី ឬតាមការកំណត់ផ្សេងផ្អែកលើលិខិតបទដ្ឋានគតិយុត្តជាធរមាន បន្ទាប់ពីទទួលបានការឯកភាពជាមុនពីក្រសួងមុខងារសាធារណៈ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា១០ .-**

អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង ត្រូវដឹកនាំដោយអគ្គនាយក១(មួយ)រូប និងមានអគ្គនាយករងមួយចំនួនតាមការចាំបាច់ ដោយអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់ភារកិច្ចអគ្គនាយកត្រូវកំណត់ដោយព្រះរាជក្រឹត្យ។ ការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់ភារកិច្ចអគ្គនាយករងត្រូវកំណត់ដោយអនុក្រឹត្យ។

នាយកដ្ឋានសវនកម្មផ្ទៃក្នុង ត្រូវដឹកនាំដោយប្រធាននាយកដ្ឋាន១(មួយ)រូប និងមានអនុប្រធាននាយកដ្ឋានមួយចំនួនតាមការចាំបាច់ ដោយអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់ភារកិច្ចប្រធាននាយកដ្ឋាន ត្រូវកំណត់ដោយអនុក្រឹត្យ។ ការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់ភារកិច្ចអនុប្រធាននាយកដ្ឋានចុះក្រោម ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួង ស្ថាប័នសាមី ឬតាមការកំណត់ផ្សេងផ្អែកលើលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ជំពូកទី៤

## ការកំណត់មុខតំណែង និងការពិពណ៌នាមុខតំណែងមន្ត្រីដែលបំពេញការងារ នៅអង្គភាពសវនកម្មផ្ទៃក្នុង

**មាត្រា១១ .-**

ការកំណត់មុខតំណែង និងការពិពណ៌នាមុខតំណែងមន្ត្រីដែលបំពេញការងារនៅអង្គភាពសវនកម្មផ្ទៃក្នុងក្រសួង ស្ថាប័ន ត្រូវកំណត់ដោយអនុក្រឹត្យតាមការស្នើរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងមុខងារសាធារណៈ។

## ជំពូកទី៥

## អន្តរប្បញ្ញត្តិ

**មាត្រា១២ .-**

លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងអគ្គាធិការដ្ឋាន អធិការដ្ឋាន និងនាយកដ្ឋានសវនកម្មផ្ទៃក្នុងក្រសួង ស្ថាប័ន ត្រូវបន្តមានសុពលភាពអនុវត្តរហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួស ស្របតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ។

មន្ត្រីរាជការស៊ីវិលនៃក្រសួង ស្ថាប័ន ដែលត្រូវបានប៉ះពាល់ដោយការរៀបចំនិងការកែសម្រួលរចនាសម្ព័ន្ធថ្មី ស្របតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ ត្រូវរក្សាទុកអត្ថប្រយោជន៍ផ្នែកបៀវត្សយ៉ាងហោចក្នុងកម្រិតដដែល។

## ជំពូកទី៦

## អវសានប្បញ្ញត្តិ

**មាត្រា១៣ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។



9

**មាត្រា១៤ ..**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៦កើត ខែស្រាពណ៍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ២០២៥

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ



តេឡេក្រាម ឯកសារមន្ត្រីសាធារណៈ